**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សាររំលែកមរណទុក្ខ

## ជូនចំពោះ

## ក្រុមគ្រួសារលោក ស៊ុំ ជួន ប្រធានក្រុមប្រឹក្សាស្រុកស្នួល ខេត្តក្រចេះ
## ចំពោះមរណភាពរបស់ លោកស្រី ទឹម សយ ជាភរិយា

**លោក ស៊ុំ ជួន ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អាន**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ និងក្នុងនាមក្រុមការងារចុះជួយខេត្តក្រចេះ មានសេចក្តីសោកស្តាយជាពន់ពេក ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **លោកស្រី ទឹម សយ** ដែលជាភរិយារបស់លោក បានទទួលមរណភាព នាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង០៦:០៥នាទីល្ងាច ក្នុងជន្មាយុ៦៩ឆ្នាំ ដោយរោគាពាធ។

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ និងក្នុងនាមក្រុមការងារចុះជួយខេត្តក្រចេះ សូមចូលរួមសម្តែងនូវ សេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុត ជាមួយ **លោក ស៊ុំ ជួន ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **លោកស្រី ទឹម សយ** ជាឧត្តមភរិយា ជាម្តាយ ជាម្តាយក្មេក និងជាជីដូនដែលប្រកបដោយសង្គហធម៌ដ៏ល្អប្រពៃ ព្រហ្មវិហារធម៌មិនចេះរីងស្ងួត ដោយមួយជីវិតរបស់លោកស្រី បានលះបង់អស់កម្លាំងកាយចិត្ត ក្នុងការចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់ជំបូន្មានល្អៗដល់កូន ចៅឱ្យក្លាយទៅជាពលរដ្ឋល្អនៅក្នុងសង្គមជាតិ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខដោយសេចក្តីសោកសង្រេងបំផុតជាមួយ **លោក ស៊ុំ ជួន ព្រមទាំងក្រុមគ្រួសារ** និងសូមសម្តែងនូវការគោរពចំពោះដួងវិញ្ញាណក្ខន្ធរបស់ **លោកស្រី ទឹម សយ** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោក ស៊ុំ ជួន ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃអង្គារ ១៣ រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ-សុខា